# FRANKLIN LEARNING CENTER

## **<u>សំណួរដែលគេឧស្សាហ៍សួរ</u>**

## ខែឧសភា ឆ្នាំ ២០២០

**ការមិនទទួលខុសត្រូវ៖** ឯកសារសំណួរដែលគេឧស្សាហ៍សួរនេះ ត្រូវបានបង្កើតឡើងនៅថ្ងៃទី ៧ ខែឧសភា ហើយព័ត៌មានទាំងនេះអាចមានការផ្លាស់ប្តូរ។ សូមចូលមើលវិបសៃ *philasd.org* ជាទៀងទាត់ ដើម្បីជ្រាបពី ការផ្លាស់ប្តូរ និង សេចក្តីជូនដំណឹងទូទាំងក្រសួង។

**+ កិច្ចការសម្រាប់មុខវិទ្យានីមួយៗ និង ការឱ្យពិន្ទុ -**

| **សំណួរ** | **ចម្លើយ** | **ព័ត៌មានបន្ថែមពីក្រសួងអប់រំ** |
|---|---|---|
| តើខ្ញុំត្រូវធ្វើដូចម្តេច បើសិនជាខ្ញុំបានរៀនធ្លាក់ក្នុងត្រីមាសទី ៣ មុនពេលដែលសាលាត្រូវបិទ? | ១) នេះគឺជាឱកាសរបស់អ្នកដើម្បីបង្កើនពិន្ទុដែលធ្លាក់! មើលសៀវភៅប្រចាំថ្នាក់របស់អ្នក ដើម្បីដឹងពីកិច្ចការដែលអ្នកមិនបានធ្វើក្នុងត្រីមាសទី ៣ (ពីខែមករា ដល់ខែមិថុនា) ហើយផ្ញើកិច្ចការដែលអ្នកធ្វើយឺតជូនគ្រូរបស់អ្នក។<br>២) សួរគ្រូរបស់អ្នក បើសិនជា Edgenuity គឺជាជម្រើសសម្រាប់ការរៀនធ្លាក់ត្រីមាសទី ២។ បើសិនជាអ្នកបានចាប់ផ្តើមហើយ សូមបញ្ចប់វាមុនដំណាច់ខែឧសភា!<br>៣) ធ្វើកិច្ចការតាមអ៊ីនធ័រណិតទាំងអស់របស់អ្នក ដែលគ្រូបានចុះផ្សាយនៅក្នុង ថ្នាក់រៀនហ្គូហ្គោល (Google Classroom) | [https://www.philasd.org/faqs/#1585255254651-06512db7-87fd](https://www.philasd.org/faqs/#1585255254651-06512db7-87fd) |
| តើខ្ញុំត្រូវរៀន ៣ ម៉ោង ជារៀងរាល់ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី ៤ ខែឧសភា នេះឬអ្វី? | មិនចាំបាច់ទេ - កាលវិភាគរបស់សិស្សម្នាក់ៗ ខុសៗគ្នា ហើយកាលវិភាគរបស់គ្រូក៏ខុសគ្នាដែរ។<br><u>កាលវិភាគសិក្សាពីផ្ទះរបស់សាលា FLC</u><br>ការផ្តល់យោបល់៖ ប្រើប្រតិទិនហ្គូហ្គោលរបស់សាលា FLC របស់អ្នក ដើម្បីរៀបចំផែនការប្រចាំសប្តាហ៍របស់អ្នក | |
| តើថ្ងៃណាជាថ្ងៃចុងក្រោយនៃការសិក្សា? | →→→ | ថ្ងៃចុងក្រោយនៃឆ្នាំសិក្សា ២០១៩-២០២០ គឺថ្ងៃទី ១២ ខែមិថុនា។ |
| តើគេចុះផ្សាយពិន្ទុត្រីមាសទី ៣ នៅថ្ងៃណា? | →→→ | បិទការឱ្យពិន្ទុនៅថ្ងៃទី ៤ ខែមិថុនា។ សូមធ្វើយ៉ាងណាសួរគ្រូរបស់អ្នកអំពីពេលវេលាដែលពួកគាត់ឈប់ទទួលកិច្ចការដែលគាត់ |

| | | |
|---|---|---|
| | | ដាក់ឱ្យសិស្សធ្វើ ព្រោះពួកគាត់ត្រូវការពេលវេលាដើម្បីដាក់ពិន្ទុទាំងអស់ មុនថ្ងៃទី ៤ ខែមិថុនា។ |
| តើខ្ញុំអាចដឹងពីពិន្ទុសរុបចុងក្រោយសម្រាប់ថ្នាក់នីមួយៗរបស់ខ្ញុំដោយវិធីណា ពីព្រោះយើងគ្មានត្រីមាសទាំងបួនផង នៅឆ្នាំនេះ? | ការគិតពីមធ្យមភាគនៃត្រីមាសទាំង ៣ អាចឱ្យអ្នកដឹងពីពិន្ទុចុងក្រោយរបស់អ្នក។ | |
| តើនឹងមានអង្គប្រជុំចែករបាយការណ៍ពិន្ទុដែរឬទេ? | គ្មានទេ ប៉ុន្តែអ្នកអាចឃើញពិន្ទុចុងក្រោយរបស់អ្នកសម្រាប់ត្រីមាសទី ៣ នៅពេលដែលគ្រូចុះផ្សាយនៅក្នុង SIS ។ រង់ចាំទទួលរបាយការណ៍ពិន្ទុចុងក្រោយ តាមសំបុត្រ។ | គ្មានទេ ពីព្រោះត្រីមាសទី ៣ ត្រូវបានពន្យារហួតដល់ខែមិថុនា យើងនឹងគ្មានរបាយការណ៍ពិន្ទុត្រីមាសទី ៣ ទេ។ គេនឹងផ្ញើឱ្យរបាយការណ៍ពិន្ទុចុងក្រោយ នៅចុងឆ្នាំ។ |
|ឃីស្តូន ត្រូវបានគេលុបចោលនៅឆ្នាំនេះ តើខ្ញុំនៅតែប្រឡងដែរឬទេ? | ព័ត៌មាននេះមិនទាន់បានសម្រេចថាយ៉ាងដូចម្តេចនៅឡើយទេ យើងនឹងផ្តល់ដំណឹងទៅសហគមន៍សាលារបស់យើង នៅពេលណាយើងបានទទួលដំណឹងថ្មី។ | សេចក្តីសម្រេចចុងក្រោយនឹងត្រូវប្រាប់ឱ្យយើងដឹងដោយរដ្ឋផិនស៊ីលវេនីញ៉ា។ |

## + បច្ចេកវិទ្យា -

| **សំណួរ** | **ចម្លើយ** | **ព័ត៌មានបន្ថែមពីក្រសួងអប់រំ** |
|---|---|---|
| តើគេចង់ឱ្យសិស្សានុសិស្សប្រគល់កុំព្យូទ័រក្រូមប៊ុកឱ្យសាលាវិញដោយវិធីណា និង នៅពេលណា? | នេះត្រូវសម្រេចដោយ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP)។ | |
| តើខ្ញុំត្រូវធ្វើដូចម្តេចបើ កុំព្យូទ័រក្រូមប៊ុក របស់ខ្ញុំខូច? | → → → | https://www.philasd.org/coronavirus/chromebooks/ ចាប់ផ្តើមពីថ្ងៃច័ន្ទ ទី ៤ ខែឧសភា |

| | | |
|---|---|---|
| | | មណ្ឌលផ្ដល់ជំនួយបច្ចេកវិទ្យា នឹងដំណើរការ ៣ ថ្ងៃក្នុងមួយសប្ដាហ៍ នៅថ្ងៃច័ន្ទ ថ្ងៃពុធ និង ថ្ងៃសុក្រ ចាប់ពីម៉ោង ៩ ព្រឹក ដល់ម៉ោង ១ រសៀល។<br><br>មជ្ឈមណ្ឌលអប់រំ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា<br>440 N. Broad Street ទីធ្លាក្នុងអាគារ ជាន់ទី ១ Philadelphia, PA 19130<br><br>អាគារបន្ថែមរបស់សាលា Fitzpatrick (ខាងក្រោយសាលាបឋមសិក្សា Fitzpatrick) 4101 Chalfont Drive, Philadelphia PA 19154 |
| ខ្ញុំមិនឃើញ Google Meets (ជួបតាមហ្គូហ្គោល) ឬ Google Class (ថ្នាក់រៀនហ្គូហ្គោល) របស់គ្រូខ្ញុំទាំងអស់ទេ។ តើខ្ញុំធ្វើអ្វីខុស? | សាលា FLC ប្រើគណនីជីម៉េល ២ ផ្សេងគ្នា ដើម្បីចូលមើលកិច្ចការសាលា - ពិនិត្យមើលម្ដងទៀត ថាតើគ្រូនីមួយៗរបស់អ្នក ប្រើ FLCHS ឬ PHILASD សម្រាប់គណនីហ្គូហ្គោលរបស់ពួកគាត់។ | *https://docs.google.com/spreadsheets/d/1LTeUQA11mUXo8NQB4DTPGutcpAW_KWBleXZqzIEDMr4/edit#gid=0* |

**- សំណួរអំពី កម្មវិធី និង អាគារ របស់សាលា FLC -**

| **សំណួរ** | **ចម្លើយ** | **ព័ត៌មានបន្ថែមពីក្រសួងអប់រំ** |
|---|---|---|
| តើគេនឹងសងប្រាក់ឱ្យសិស្សានុសិស្សវិញ សម្រាប់កម្មវិធីរបស់សាលាដែលគេបានលុបចោល ដែលសិស្សបានទិញសំបុត្ររួចហើយនោះ ដែរឬទេ?<br>(ឧ. Dodgeball, School Dance, Prom) | សំបុត្រដែលបានទិញហើយ ហើយគេបានកត់ទុកជាឯកសារ នឹងត្រូវគេសងប្រាក់វិញ។ នៅពេលនេះគេមិនទាន់បានសម្រេចពី ពេលវេលា និង វិធី សងប្រាក់នោះនៅឡើយទេ។ | |
| តើនឹងមានការផ្លាស់ប្ដូរចំនួនម៉ោងនៃការបម្រើសហគមន៍ ដែលគេតម្រូវឱ្យសិស្សានុសិស្សធ្វើនៅឆ្នាំនេះដែរឬទេ? | នេះគឺជាសំណួរដែលយើងនឹងពិនិត្យមើលឡើងវិញ នៅពេលដែលយើងដឹងបន្ថែមទៀត អំពី កាលវិភាគរបស់សាលា និង ស្ថានភាពសង្គមរបស់យើងទាំងមូល នៅឆ្នាំក្រោយនេះ។ | |

| | | |
|---|---|---|
| តើសិស្សានុសិស្សអាចទៅយកសម្ភារៈផ្ទាល់ខ្លួនមកវិញ មុនឆ្នាំសិក្សានេះចប់ដែរឬទេ? | មកដល់ពេលនេះ អត់បានទេ។ សិស្សានុសិស្សដែលត្រូវត្រឡប់មកសាលានេះវិញ នឹងមិនអាចបើកទូដាក់សម្ភារៈរបស់ពួកគេបានទេរហូតដល់ឆ្នាំក្រោយ។ គេប្រហែលជាអាចរៀបចំឱ្យសិស្សថ្នាក់បញ្ចប់បានខ្លះ បើសិនជាសាលាត្រូវការប្រើទូដាក់សម្ភារៈរបស់ពួកគេនៅឆ្នាំសិក្សាក្រោយនេះ។ | |
| តើខ្ញុំត្រូវប្រគល់សៀវភៅឱ្យសាលាវិញយ៉ាងដូចម្ដេច បើសិនជាខ្ញុំជា សិស្សថ្នាក់បញ្ចប់ ឬ ជាសិស្សដែលត្រូវត្រឡប់មកសាលានេះវិញនៅឆ្នាំក្រោយ? (ឧ. សៀវភៅមេរៀន សៀវភៅរបស់បណ្ណាល័យសាលា សៀវភៅអានពីគ្រូម្នាក់ៗ) | យើងកំពុងរង់ចាំការឆ្លើយតបពីក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) ទាក់ទងនឹងពេលវេលាដែលគេនឹងអនុញ្ញាតឱ្យសិស្សានុសិស្សអាចត្រឡប់ចូលក្នុងអាគារសាលាវិញ។ | |

## - សិស្សថ្នាក់បញ្ចប់ -

| **សំណួរ** | **ចម្លើយ** | **ព័ត៌មានបន្ថែមពីក្រសួងអប់រំ** |
|---|---|---|
| តើគេនឹងសងប្រាក់ឱ្យសិស្សវិញសម្រាប់កម្មវិធីរបស់សាលាដែលគេបានលុបចោល ដែលសិស្សបានទិញសំបុត្ររួចហើយនោះ ដែរឬទេ? (ឧ. Dodgeball, School Dance, Prom) | សំបុត្រដែលបានទិញហើយ ហើយគេបានកត់ទុកជាឯកសារ នឹងត្រូវគេសងប្រាក់វិញ។ នៅពេលនេះគេមិនទាន់បានសម្រេចពី ពេលវេលា និង វិធី សងប្រាក់នោះនៅឡើយទេ។ | |
| បើសិនជាខ្ញុំជាសិស្សថ្នាក់បញ្ចប់ តើខ្ញុំត្រូវប្រគល់សៀវភៅឱ្យសាលាវិញដោយវិធីណា និង នៅពេលណា? (ឧ. សៀវភៅមេរៀន សៀវភៅរបស់បណ្ណាល័យសាលា សៀវភៅអានពីគ្រូម្នាក់ៗ) | នៅពេលណាយើងបានទទួលដំណឹងពីក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) យើងនឹងជូនដំណឹងដល់សិស្សអំពីជំហានបន្ទាប់។ | |

| | | |
|---|---|---|
| តើយើងនឹងនៅតែមានពិធីបញ្ចប់ការសិក្សាដែរឬទេ? | **សាលា FLC កំពុងរៀបចំពិធីបញ្ចប់ការសិក្សាតាមអ៊ីនធឺណិត ដែលនឹងធ្វើឡើងនៅថ្ងៃទី ១០ ខែមិថុនា**<br><br>**ថ្ងៃទី ៦ ខែមិថុនា ម៉ោង ៣ រសៀល**<br>*Reach Higher នឹងចាប់ផ្តើមពិធីអបអរសាទរជាមួយ លោកស្រី* Michelle Obama ចុះឈ្មោះនៅទីនេះ៖<br>[https://www.reachhigher.org/virtual-commencement/](https://www.reachhigher.org/virtual-commencement/) | យើងដឹងអំពីសារៈសំខាន់នៃការរៀបចំពិធីដ៏សំខាន់នេះ សម្រាប់ សិស្សានុសិស្ស និង ក្រុមគ្រួសារ។ រហូតមកដល់ពេលនេះ នៅមិនទាន់មានសេចក្តីសម្រេចជាផ្លូវការអំពីពិធីបញ្ចប់ការសិក្សានៅឡើយទេ។ យើងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងសុខភាពសាធារណៈនៃទីក្រុងហ្វីឡាដែលហ្វ្យា ដើម្បីតាមដានស្ថានភាពនៃមេរោគ ខូវីដ-១៩ ជាប្រចាំ និង សម្រេចពីជំហ៊ានបន្ថែមទៀតដែលយើងត្រូវធ្វើនៅពេលដែលពេលវេលានៃការបញ្ចប់ការសិក្សាកាន់តែខិតជិតមកដល់។ នៅក្នុងពេលនេះ យើងកំពុងពិនិត្យមើលយ៉ាងសកម្មនូវអ្វីដែល តំបន់ផ្សេងៗ និង សាកលវិទ្យាល័យដទៃទៀត បានលុបចោលពិធីបញ្ចប់ការសិក្សា និងកំពុងធ្វើអ្វីៗដើម្បីគាំទ្រដល់ សិស្សានុសិស្សថ្នាក់បញ្ចប់ និង ក្រុមគ្រួសារ របស់ពួកគេ ហើយស្វែងយល់ពីជម្រើសផ្សេងៗ នៅពេលណាដែលមានការចាំបាច់ត្រូវលុបចោលកម្មវិធី សម្រាប់ក្រសួងអប់រំរបស់យើង។ |
| តើគេនឹងផ្ញើសញ្ញាប័ត្រឱ្យដែរឬទេ បើសិនជាគ្មានពិធីបញ្ចប់ការសិក្សានៅឆ្នាំនេះ? | ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា (SDP) ជាអ្នកផ្ញើសញ្ញាប័ត្រឱ្យ យើងនឹងផ្តល់លិខិតបែបបទហ្គូហ្គោលឱ្យសិស្សដើម្បីបំពេញប្រាប់ពីអាស័យដ្ឋានដែលត្រឹមត្រូវដើម្បីឱ្យគេផ្ញើសញ្ញាប័ត្រឱ្យ។ | ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ប្តេជ្ញាធ្វើយ៉ាងណាឱ្យសិស្សថ្នាក់បញ្ចប់ទាំងអស់ទទួលបានសញ្ញាប័ត្ររបស់ខ្លួន ទោះបីជាយើង អាច ឬ មិនអាច ប្រារព្ធពិធីបញ្ចប់ការសិក្សាតាមប្រពៃណី នៅក្នុងខែមិថុនា នេះក៏ដោយ។ |
| តើយើងនៅតែត្រូវបង់ថ្លៃ ថ្នាក់/ការបញ្ចប់ការសិក្សា ដែរឬទេ? តើថ្លៃថ្នាក់របស់យើងនឹងត្រូវគេសងវិញ | យើងកំពុងរង់ចាំគេដឹកមកឱ្យ សៀវភៅប្រចាំឆ្នាំ មួក និង រ៉ូប (gowns) របស់យើង ហើយយើងបានរៀបចំសញ្ញាប័ត្ររួចរាល់ | បើសិនជាអ្នកមិនទាន់បានបង់ប្រាក់ទាំងនេះទេ អ្នកមិនគួរបង់ទេ។ បើសិនជាអ្នកបានបង់ប្រាក់សម្រាប់សម្ភារៈដែលគេនឹង |

| | | |
|---|---|---|
| ឬទេ បើសិនជាយើងបានបង់ប្រាក់រួចហើយ? | ហើយ។ នៅពេលណាយើងទទួលការអនុញ្ញាតឱ្យចែកចាយសម្ភារៈទាំងនោះ យើងនឹងធ្វើការចែកចាយភ្លាម។ | ដឹកមកឱ្យ អ្នកនឹងទទួលបានសម្ភារៈទាំងនោះនៅពេលណាដែលមានសុវត្ថិភាពក្នុងការចែកចាយ។ បើមិនដូច្នោះទេ យើងសុំឱ្យអ្នកមានការអត់ធ្មត់ ក្នុងពេលដែលសាលារបស់យើងកំពុងគិតលម្អិតពីវិធីសងប្រាក់វិញទៅក្រុមគ្រួសារ។ ការសងប្រាក់នឹងមានលក្ខណៈខុសៗគ្នារវាងសាលានីមួយៗ ហើយយើងមាន ជម្រើស និង វិធីជាច្រើន ដើម្បីជ្រើសរើស។ |

***ការមិនទទួលខុសត្រូវ៖*** ឯកសារសំណួរដែលគេឧស្សាហ៍សួរនេះ ត្រូវបានបង្កើតឡើងនៅថ្ងៃទី ៧ ខែឧសភា ហើយព័ត៌មានទាំងនេះអាចមានការផ្លាស់ប្តូរ។ សូមចូលមើលវិបសៃ *philasd.org* ជាទៀងទាត់ ដើម្បីជ្រាបពី ការផ្លាស់ប្តូរ និង សេចក្តីជូនដំណឹងទូទាំងក្រសួង។